# ស័ង្ខសិល្បជ័យ

## ភាគទី៨

កេសរសុមន្ទាស្ដាប់ហើយឆ្លើងថា: "ក្នុងព្រះគាថា ស្រីណាដែលសម្លាប់ប្ដីតែងកើតកម្មវេរា ហើយធ្លាក់អវីចីដែរដូចបុត្រដឹងស្រាប់។ ឬមួយក៏ចាំមាតាឲ្យយក្សជូនទៅវិញ?"

គេប្រាកដជាមិនជូនមាតុច្ឆាទៅឡើយ។

បើដូច្នេះចូរបុត្រ រងចាំសិនចុះ ចាំមាតាសុំយក្សសិន។ កេសរសុមន្ទាក៏រៀបចំអាហារថ្វាយព្រះពោធិសត្វ ហើយក៏លាក់ខ្លួនសិន។

យើងស្ទេះត្រឹមនេះសិន និយាយពីកុម្ភ័ណយក្សាដែលបេះផ្កាក្នុងព្រៃ ហេតុតែចាញ់បារមីព្រះពោធិសត្វ បណ្ដាលឲ្យកុម្ភ័ណឈឺក្បាលធ្វើអ្វីមិនកើតក៏ប្រញាប់ត្រលប់មកមណ្ឌលវិញ។ លុះចូលដល់ប្រាសាទក៏ថា: "ដូចជាមានធំក្លិនមនុស្ស"។ កេសរសុមន្ទាស្ដាប់ហើយ ធ្វើកលនិយាយថា: អ្នកទៅក្រៅមានស្រី ហើយមកថាធំក្លិនទៅវិញ?

បងគ្មាននរណាទេក្រៅពីប្អូន បងទៅបេះផ្កាក្នុងព្រៃ ហើយកាលដែលបងមកយឺតព្រោះតែបងឈឺក្បាលពេក។ កេសរសុមន្ទាធ្វើកលនិយាយថា: "ខ្ញុំយល់សុបិន្តឃើញព្រះរៀមរាជាឯនាយ។ លុះភ្ញាក់ឡើងខ្ញុំនឹកអាល័យព្រះរៀមណាស់ សូមម្ចាស់បងជូនប្អូនទៅលេងផង..."។

មិនបានទេបងមិនឲ្យប្អូនទៅទេ ព្រះរៀមឯនាយទ្រង់ប្រាកដជាបានសុខហើយដូច្នេះចូរប្អូនកុំទៅថ្វី ទោះយ៉ាងណាក៏បងមិនឲ្យទៅដែរលើកលែងតែបងស្លាប់...។ និយាយតែប៉ុណ្ណោះ កុម្ភ័ណ្ឌប្រះប្រាណដេកលក់ព្រងើយ ទោះបីកេសរសុមន្ទាដាស់អង្រួនយ៉ាងណាក៏មិនភ្ញាក់ដែរ។ ទតឃើញដូច្នោះព្រះពោធិសត្វក៏ចេញមកហើយសួរមាតុច្ឆាថា: "គិតម្ដេចទៅព្រះមាតុច្ឆា យក្សមិនឲ្យទៅទេ។ ឥឡូវនេះ

អត្ថបទដោយ៖ មាស សុភាព

អញ្ជើញព្រះមាតុច្ឆាទៅជាមួយខ្ញុំ៉ៗ កេសរសុមន្ទាយល់ក្ដួយបង្ខំដូច្នោះ ក៏សោយសោកឱបព្រះបាទាប្ដីហើយថា:

អ្នកធ្វើតោះតើយ អ្នកផ្ទះព្រងើយ ពុំដឹងអាត្មា
ពីថ្ងៃនេះហើយ អ្នកអើយយល់ជា យើងពុំយល់គ្នា
ដូចកាលប្រក្រតី។
ឱអ្នកនិងប្អូន បង្កើតជាកូន កូនសោតជាស្រី
ព្រាត់ប្រាសចេញទៅ លំនៅទីទៃ ជិតដោយនឹងប្ដី
ពុំយល់មុខម្ដាយ។
នៅណ៉ាអ្នកណ៉ា ប្អូនសូមក្រាបលា លាទៅថ្កានបង
កុំអ្នកថាខ្ញុំ ពិតពុំស្នេហ៍ស្នង អាល័យណាស់ហោង
ម្ដេចឥឡូវហើយ។

ស័ង្ខសិល្បជ័យទតឃើញមាតុច្ឆាដូច្នោះ ក៏តឿន។ កេសរសុមន្ទាចេញដល់ទ្វារក៏លោមបុត្រថាក្មេចព្រះភស្ត្រ លុះត្រឡប់មកក៏ដាស់អង្រួនស្វាមីក្ដិចផងខ្វារក្រញៅយ៉ាងណាក៏មិនភ្ញាក់ដែរ។ ស័ង្ខសិល្បជ័យតឿនមាតុច្ឆាម្ដងទៀតលុះចេញដល់ទ្វារ ក៏ថាក្មេចស្មៀតសក់ លើកក្រោយទៀត ថាក្មេចក្រវិលមាស...។ស័ង្ខសិល្បជ័យយល់មាតុច្ឆាដូច្នោះក៏ខឹងក្រោធហើយថា:

ថាបើអ្នកនឹងនៅ មិនព្រមទៅនឹងខ្ញុំឡើយ
ខ្ញុំលាក់អ្វីអ្នកអើយ ខ្ញុំនឹងកាត់យកសិរសា។
នែអ្នកនាំទៅថ្វាយ ក្សត្រឯនាយជាបិតា
កុំឲ្យស្ដេចសង្កា ថាខ្ញុំមកពុំបានដល់។

អត្ថបទដោយ៖ មាស សុភាព

កេសរសុមន្ទា ឮបុត្រនិយាយដូច្នោះភិតភ័យ ហើយក៏ផ្ដាំទ្វារថាលាហើយ។ ព្រះពោធិសត្វនាំព្រះមាតុច្ឆាចាកចេញទៅទាំងយប់ដោយមានស័ង្ខជាអ្នកនាំមុខ។ លុះបានដល់ព្រះគុហាមាសមួយ ព្រះពោធិសត្វក៏ចូលទៅសម្រាកនិងសោយអាហារទិព្វទីនោះ។ សោយរួចទ្រង់ប្រាប់មាតុច្ឆាថា ខ្លួននឹងទៅច្បាំងជាមួយយក្សកេសរសុមន្ទាឮដូច្នោះក៏ភ័យណាស់ ក៏លោមបុត្រថាៈ “មាសថ្លើមថ្ងៃកុំសម្លាប់គេអី ខ្លាចកើតកម្មវេរា...”។ ព្រះពោធិសត្វចាកចេញទៅដោយយកថ្មស្ទះទ្វារគុហាយ៉ាងមាំ។ លុះទៅដល់ប្រាសាទកុម្ភ័ណ្ឌ ស័ង្ខសិល្បជ័យក៏ដកព្រះខ័នកាត់ដាច់ក ភ្លាមនោះយក្សក៏កើតទៅជាប្រាំពីរ។ លុះសម្លាប់ប្រាំពីរ ក៏កើតទៅជាប្រាំពីរៗដង គឺសែសិបប្រាំបួន ព្រះពោធិសត្វក៏កាប់អស់សែសិបប្រាំបួនទៀត។ បន្តទៀតក៏កើតជារយពាន់សែន តែក៏នៅតែចាញ់ដៃព្រះពោធិសត្វ ទតឃើញយក្សចាញ់ដៃដូច្នោះព្រះពោធិសត្វក៏វិលមកគុហាវិញ ហើយនាំព្រះមាតុច្ឆាចេញទៅ។ ចំណែកកុម្ភ័ណ្ឌក៏កែនបានយក្សជាច្រើន មកតាមឡោមព័ទ្ធព្រះពោធិសត្វ ដោយមិនបានហៅបងមកជួយទេ ព្រោះបងដេកលក់នឹងដាស់មិនភ្ញាក់ឡើយ។ ព្រះពោធិសត្វទតឃើញដូច្នោះ ក៏សរសេរអក្ខរាបិទមុខសរ ហើយថ្លែងសំដៅរាជសីហ៍។ រាជសីហ៍ទទួលបានសរហើយ ក៏ប្រញាប់ផ្ដេរផ្ដាំទេវតាឲ្យរក្សាស្ដេចទាំងប្រាំមួយ ហើយហោះសំដៅទៅរកស័ង្ខសិល្បជ័យ...។ ស័ង្ខសិល្បជ័យគង់លើរាជសីហ៍ប្រយុទ្ធនឹងអ្នករាប់សិបនាក់ យក្សបានប្រែកាឡាខ្លួនជាច្រើនរូបភាព ក៏នៅតែមិនអាចយកជ័យជំនះលើស័ង្ខសិល្បជ័យបានឡើយ។ ទីបំផុតស័ង្ខសិល្បជ័យបានថ្លែងសរត្រូវចំកុម្ភ័ណ្ឌធ្លាក់ចុះកើតជាអគ្គីឆេះភ្លឺរន្ទាលដល់ឋានតាវត្តិង្ស ស័ង្ខសិល្បជ័យឃើញដូច្នោះក៏ចោលស័ង្ខក្លាយជាទឹកពន្លត់ភ្លើង...។

អត្ថបទដោយ៖ មាស សុភាព

កុម្ភ័ណ្ឌប្រះប្រាណដេកលើដី ស្រែកហៅកេសរសុមន្ទាថា: "ហៃនាងសុមន្ទា នាងឲ្យក្ដួយនាងមហិមា សម្លាប់យើងឆាប់រ៉ា ឫទ្ធិអញអស់ម៉្លេះហើយ នឹងរស់នៅក៏គ្មានប្រយោជន៍អ្វីឡើយ" ព្រះពោធិសត្វឃើញដូច្នោះ ទ្រង់កាន់ព្រះខ័នកាប់យក្សដល់ក្ដីមរណាក្នុងពេលនោះទៅ។ កាលនោះទេពតាយល់ព្រះពោធិសត្វបានជោគជ័យលើយក្សទាំងឡាយ ក៏ហោះកាន់ផ្កាមកថ្វាយបាចសាច ចម្រើនពរសព្ទសាធុការអឺងអាប់។

ចំណែកកេសរសុមន្ទាទ្រង់ក៏សោយសោកពិលាបអាណិតកុម្ភ័ណ្ឌរៀបរាប់:

ថាឱព្រះជេស្ឋជ័យ ហេតុវិបាកព្រះអង្គឯង
វេរាពីមុនជាតិ ឲ្យឃ្លាឃ្លាតចេញរង្វេង
ខ្ញុំឃាត់ត្បិតខ្ញុំក្រែង ស្ដេចពុំដោយដូចខ្ញុំឃាត់។
ស្ដេចអាងអួតចេស្ដា ឫទ្ធិពលាពន់ពេកក្ដាត់
ពុំអន់ពុំឱនអត់ ក្រោធពិរោធពិរុលក្រៃ។
ឥឡូវប្រោសពីឋាន ព្រៃហិមពាន្តពិសេសសម
បពិត្រស្ដេចមកផ្ដុំ លើក្រឡាមហាប្រឹថពី។
ខ្ញុំប្រាសប្រាណទីទៃ ស្វាត់ពីថ្ងៃនេះទៅហើយ
ឱព្រះអង្គត្រាណត្រើយ ខ្ញុំពុំយល់ព្រះភក្ត្រា។
ឱកូនសោតនិរាស ព្រាយព្រាត់ប្រាសពុំយល់គ្នា
ម្ល៉េះហើយសមឃ្លាតឃ្លា នៃនឹងបុត្រពុំយល់ឡើយ។

"ឱព្រះអង្គធ្លាប់នៅសំណេះសំណាលឆ្លើយឆ្លងក្នុងទីមណ្ឌល ពេលនេះខ្ញុំមិនបានរៀបចំរាជបរិក្ខារលើព្រះសពបងទេ សូមអ្នកកុំសង្កាថ្វី..."។ កេសរសុមន្ទាហេតុអាស្រ័យស្រណោះកុម្ភ័ណ្ឌពេក ទ្រង់សោយសោករហូតដល់សន្ទប់

អត្ថបទដោយ៖ មាស សុភាព

បាត់ស្មារតី។ ស័ង្ខសិល្បជ័យយល់ព្រះមាតុច្ឆាទ្រង់សែនសោយសោកដូច្នោះ ក៏លោមមាតុច្ឆា ហើយរៀបចំសម្ដែងឫទ្ធិសិល្ប៍សរជាប្រាសាទប្រាំស្អាងស្អាត សមបវរតម្កល់សព ហើយទ្រង់ថ្វាយព្រះភ្លើង...។

លុះព្រះសពសុសសព្វហើយ ព្រះពោធិសត្វក៏ទ្រង់ថ្វៃងសរសិល្ប៍ជាប្រាសាទកែវរចនាភ្លឺប្រាលដល់វេហាស៍ រួចយកព្រះធាតុដាក់តម្កល់ទីនោះ ហើយទ្រង់ក៏អធិដ្ឋានដើម្បីលាកម្មពៀរវេរាជាមួយកុម្ភ័ណ្ឌ...។

(សូមដានរឿង ស័ង្ខសិល្បជ័យ ភាគទី៩ នៅសប្ដាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព